 21-07

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៤៣ ស.ស.រ.

# សេចក្តីសម្រេច
# ស្តីពីការបង្កើតគណៈកម្មការ
# ដើម្បីកំណត់អាសនៈរដ្ឋសភាសម្រាប់នីតិកាលទី៥

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងមាត្រា៧ និងមាត្រា៨ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៧ /០៦ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៧
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតគណៈកម្មការកំណត់អាសនៈរដ្ឋសភាសម្រាប់នីតិកាលទី៥ ដែលមានសមាសភាពដូចខាងក្រោម ÷

| | |
|---|---|
| ១-តំណាងគណបក្សប្រជាជនកម្ពុជា | មួយរូប |
| ២-តំណាងគណបក្សសមរង្ស៊ី | មួយរូប |
| ៣-តំណាងគណបក្សសិទ្ធិមនុស្ស | មួយរូប |
| ៤-តំណាងគណបក្សហ៊្វុនស៊ិនប៉ិច | មួយរូប |
| ៥-តំណាងគណបក្សនរោត្តមរណឫទ្ធិ | មួយរូប |
| ៦-តំណាងក្រសួងមហាផ្ទៃ | ពីររូប |
| ៧-នាយកនៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ | មួយរូប |

ប្រការ ២._

គណៈកម្មការនេះដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយរូប ដែលជ្រើសតាំងក្នុងចំណោមសមាជិកគណៈកម្មការដោយការបោះឆ្នោតតាមមតិភាគច្រើនដាច់ខាតពីសមាជិកគណៈកម្មការនេះ ។

ប្រការ ៣._

គណៈកម្មការខាងលើនេះត្រូវធ្វើរបាយការណ៍ និងលើកសំណើជូនរាជរដ្ឋាភិបាលអំពីការបន្ថែមអាសនៈ ឬការរក្សាទុកចំនួនអាសនៈនៅដដែល ដោយផ្អែកលើស្ថានភាពប្រជាពលរដ្ឋ ស្ថានភាពភូមិសាស្ត្រ សង្គម និងសេដ្ឋកិច្ច ។

ប្រការ ៤._

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រី រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋាន គ្រប់ក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាល និងសមាសភាពដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**

*-ក្រសួងព្រះបរមរាជវាំង*

*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*

*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*

*-អគ្គលេខាធិការរាជរដ្ឋាភិបាល*

*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*

*-ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*

*-ដូចប្រការ ៤ "ដើម្បីអនុវត្ត"*

*-រាជកិច្ច*

*-ឯកសារ កាលប្បវត្តិ*